**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៧៦
ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥
**សាលដីកា**
លេខ:៣១៥
ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម .......... ជាប្រធាន
២-លោក ............ ជាចៅក្រម
៣-លោក ............ ជាចៅក្រមរបាយការណ៍
៤-លោក .............. ជាចៅក្រម
៥-លោក .............. ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**
-លោក ................

**តំណាងមហាអយ្យការ**
-លោក ................. ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៩២(ក)ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៨១៣ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍វាង :

ដើមចោទឈ្មោះហវ(ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរមុខរបរធ្វើស្រែ ទីលំនៅក្រុមទី១៥ ភូមិក្ងាវ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ។

មានមេធាវីលោក............... ។

ចុងចម្លើយឈ្មោះធហ (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរមុខរបរលក់ដូរ ទីលំនៅក្រុមទី១៥ ភូមិក្ងាវ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ។

ផ្ទេរសិទ្ធិឱ្យអ្នកស្រី ហធត ។

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងទាមទារដី និងរុះរើសំណង់ចេញពីដីទំនាស់

បានឃើញបណ្តឹងសាទុក្ខលេខ៧៧ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០១ របស់ឈ្មោះលីធីតា ប្តឹងមិនសុខចិត្ត និងសាលដីការដ្ឋប្បវេណីលេខ៩២(ក) ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៧៦ចុះថ្ងៃទី២៥ ខែមីនាឆ្នាំ២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៩-០៤-១៩៩៩ របស់ភាគីដើមចោទឈ្មោះហាវនិងឯកសារ នៃអង្គហេតុបានបញ្ជាក់ថា ដើមចោទប្តឹងទាមទារកាន់កាប់ និងគ្រប់គ្រងដីភូមិទំហំ២៨០ម² ដែលមានទីតាំងស្ថិតនៅភូមិក្អាវ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ពីចុងចម្លើយឈ្មោះធហ ដែលបានរំលោភយកដីកម្មសិទ្ធិរបស់ខ្លួនដោយបានសំអាងហេតុថា ដីទំនាស់នេះខ្លួនបានកាន់កាប់តាំង ពីឆ្នាំ១៩៧៩ រហូតមកមានសង់លំនៅដ្ឋានដាំដំណាំ ។ លុះដល់ឆ្នាំ១៩៨៩ ដោយស្រុកទេសមាន សង្គ្រាម ក្រុមគ្រួសារខ្លួនក៏បានភាសសឹកទៅឆ្ងាយ ហើយនៅឆ្នាំ១៩៩៦ ពេលស្រុកមានសន្តិភាព ក្រុមគ្រួសារខ្លួនក៏ត្រឡប់ចូលស្រុកវិញ ពេលនោះខ្លួនឃើញឈ្មោះធហ បានសាងសង់ផ្ទះ និងរស់នៅលើដីរបស់ខ្លួន ។ នៅថ្ងៃទី០២-០៣-១៩៩៧ ខ្លួនបានទៅសុំដីនៅខាងក្រោយ តែឈ្មោះធហ មិនព្រមឱ្យពេលនោះក៏មានការប្តឹងគ្នាទៅភូមិ ។ ដីទំនាស់នេះមានការដោះស្រាយជាបន្តបន្ទាប់នៅថ្នាក់រដ្ឋអំណាចមូលដ្ឋានពីថ្នាក់ភូមិរហូតដល់ស្រុក តែពុំអាចផ្សះផ្សាគ្នាបាន ។ ដីទំនាស់ មានព្រំប្រទល់គឺ :

-ខាងជើងទល់ថ្នល់ជាតិលេខ១០A

-ខាងលិចទល់ថ្នល់ជាតិលេខ១០B

-ខាងកើតទល់ដីរបស់ឈ្មោះប៊ុច ជឿន

-ខាងត្បូងទល់ដីរបស់ឈ្មោះដឹម យិ ។

ដោះសារចំពោះបណ្តឹងទាមទាររបស់ដើមចោទ ភាគីចុងចោទឈ្មោះធហ បានបញ្ជាក់ថា ដីទំនាស់នេះ ខ្លួនបានទិញពីឈ្មោះសោម សុខុម ជានគរបាលក្នុងតម្លៃ៣៣០០០០៛ ដោយមានកិច្ចសន្យាត្រឹមត្រូវ ។ កាលពីមកស្នាក់នៅដំបូងនៅឆ្នាំ១៩៩៧ ដីនេះជាដីព្រៃ និងមានបង្កប់មីន ដូចនេះខ្លួនជាអ្នកកាប់ឆ្កា និងដោះមីនដោយខ្លួនឯង។លុះដល់ឆ្នាំ១៩៩៨ទើបឈ្មោះហិន វន បានប្តឹងទាមទារដីនេះពីខ្លួន ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ២៣៧ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៩ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

ក-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩ និងសំណូមពរនាពេលសាវនាការ របស់ដើមចោទឈ្មោះហាវប្តឹងសុំគ្រប់គ្រងកាន់កាប់ដីទំនាស់ជាកម្មសិទ្ធិ និងប្តឹងសុំឱ្យចុងចម្លើយឈ្មោះធហ រុះរើចេញពីដីទំនាស់ដោយឧបត្ថម្ភការរុះរើ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

ខ-ទទួលសំណូមពររបស់ចុងចម្លើយឈ្មោះធហ ប្តឹងសុំគ្រប់គ្រងកាន់កាប់ដី ទំនាស់ជាកម្មសិទ្ធិទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយ នឹងគតិច្បាប់ ។

II-ប្រគល់ដីទំនាស់ស្ថិតនៅភូមិក្អាវ ឃុំត្រែង ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ឱ្យដល់ដើមចោទឈ្មោះហាវគ្រប់គ្រងកាន់កាប់ជាកម្មសិទ្ធិស្របច្បាប់ គិតយកជាមូលដ្ឋានតាមប្លង់ទីតាំងបង្ហាញដីទំនាស់ចុះថៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៩ របស់មន្ទីរសុរិយោដីខេត្តបាត់ដំបងក្នុង ទំហំFCDEF មានផ្ទៃក្រឡា២៩៦ម² ដែលមានជ្រុង CD=៣៣,៩៤ម DE=៧,៨០ម EF=២៩,៥០ម និង FC=១៣០០ម និង

ឱ្យចុងចម្លើយឈ្មោះធហ រុះរើផ្ទះចេញពីដីនេះដោយឱ្យដើមចោទឈ្មោះហវឧបត្ថម្ភការរុះរើចំនួន ២០០០ បាតប្រាក់ថៃចាប់ពីថ្ងៃដែលសាលក្រមចូលជាស្ថាពរ ។

II-ឱ្យចុងចំលើយឈ្មោះធហ បង់ប្រាក់ប្រដាប់ក្ដីគឺ :

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្មឹង១៨០០៛

-រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛

-ចំណាយស៊ើបសួរ៥០០០៛ សរុប៧០០០៛ ។

ប្រាក់នេះបានកាត់យកពីប្រាក់ដែលដើមចោទបានបង់រួចហើយ កាលបើហួសឧទ្ធរណ៍ ឱ្យចុងចម្លើយសងប្រាក់ចំនួន៧០០០៛ ទៅដើមចោទវិញ និងឱ្យចុងចម្លើយឈ្មោះធហ បង់ពន្ធសមាមាត្រចំនួន ១២.០០០៛ ប្រាក់នេះកាត់៨០% បង់ចូលថវិការដ្ឋសល់២០% ដាក់ចូលហិបប្រាក់ ក្រឡាបញ្ជីទូទាំងព្រះរាជាណាចក្រកម្ពុជា ។

តាមអនុក្រឹត្យលេខ២៥អនក្រ ចុះថ្ងៃទី២២ខែមករាឆ្នាំ១៩៨៩ តាមមាត្រា៣.៥.១៩.២០.២៨.៦២,៦៤.៦៥.៦៨.៧៤ នៃច្បាប់ភូមិបាល ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ១០០ក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ និងតាមច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៧ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ។

IV-សាលក្រមនេះជំនុំជំរះ ប្រកាស់ជាសាធារណៈចំពោះមុខគូក្ដី ។ បើកផ្លូវឧទ្ធរណ៍ពីរខែ គិតពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ១១៥ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់ឈ្មោះធហប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២៣៧ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៩ របស់តុលាការ ខេត្តបាត់ដំបង ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤៦(ក) ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ១១៥ ចុះថ្ងៃទី១៨-១១-១៩៩៩ របស់ឈ្មោះធហ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមលេខ២៣៧ ចុះថ្ងៃទី២០-១០-១៩៩៩ របស់តុលាការខេត្ត បាត់ដំបង ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីដាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ ដែលដើមបណ្ដឹង ឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្មឹងចំនួន២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការចំនួន៥០០០៛ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខហាវកំបាំងមុខធហ ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ៥១ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០០ របស់ឈ្មោះធហ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៤៦ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩២(ក) ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី០៨-០៥-២០០០ របស់ឈ្មោះធហ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាលេខ៤៦(ក)ចុះថ្ងៃទី២៥-០៨-២០០០ របស់សាលាឧទ្ធរណ៍ទុកជាមុនការពេញទាំងមូល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈកំបាំងមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ គិតចាប់ពីថ្ងៃទទួលដំណឹង ។

បានឃើញបណ្តឹងសាទុក្ខលេខ៧៧ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០១ របស់ឈ្មោះលី ធីតា ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៩២(ក) ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៦ របស់ឈ្មោះធហ ។

បានឃើញសារណាតបចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះហាវ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ រឿងនេះជាវិវាទប្តឹងទាមទារដី សូមក្រុមប្រឹក្សាជំនុំជំរះសម្រេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះហធត នាពេលសវនាការថា ដីនេះខ្លួនបានទិញពី ប៉ូលីសឈ្មោះសោម សុខុម ជាដីព្រៃនៅឆ្នាំ១៩៩៧ ទើបតែនៅឆ្នាំ១៩៩៨-១៩៩៩ ទើបឈ្មោះហាវប្តឹងទាមទារ ។ លើដីនេះខ្លួនបានធ្វើផ្ទះរស់នៅ និងលក់ដូរនៅមុខផ្ទះ ។

សុំឱ្យតុលាការជួយរកយុត្តិធមិឱ្យខ្លួនផង ។

បានស្តាប់ចម្លើយរបស់ឈ្មោះហាវនាពេលសវនាការថា ដីនេះខ្លួនរស់នៅតាំងពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៨៩ ប្រទេសជាតិកើតសង្គ្រាម រដ្ឋាភិបូលបានជំលៀសចេញពីភូមិមួយរយៈសិន ហើយនៅឆ្នាំ១៩៩៦ ប្រទេសជាតិមានសន្តិភាព ខ្លួនក៏ត្រឡប់មកវិញ ស្រាប់តែឃើញឈ្មោះធហ ចូលរស់នៅ ។ សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកស៊ឹម ស៊ីថាន ជាមេធាវីការពារឱ្យដើមចោទ បាន លើកឡើងថា : ដីទំនាស់នេះ កូនក្តីខ្លួនកាន់កាប់តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ ក៏ចាកចេញមួយរយៈសិន ដោយប្រទេសមានសង្គ្រាម ។

សំណូមពរសុំឱ្យតុលាការកំពូលសម្រេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូលល ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ .

ក្រោយពីបានពិភាក្សត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៧៧ ចុះថ្ងៃទី១៥-០៣-២០០១ របស់ឈ្មោះធហ បានធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

.យល់ឃើញថា ការបញ្ជាក់របស់រដ្ឋអំណាចមូលដ្ឋាន និងចម្លើយរបស់សាក្សីនៃទីតាំងដីទំនាស់ គឺជាភស្តុតាងបញ្ជាក់ថា ភាគីដើមចោទឈ្មោះហវពិតជាបានកាន់កាប់ដីទំនាស់ជាប់ ជាអចិន្ត្រៃយ៍រហូតដល់ឆ្នាំ១៩៨៩ និងក្រោយមកបានបោះបង់មួយរយៈដោយហេតុផលសង្គ្រាមប្រាកដមែន រីឯចុងចម្លើយ បានលទ្ធកម្មដោយសារកិច្ចសន្យាចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩៧ ទិញដីពីឈ្មោះសោម សុខុម មុខរបរនគរបាល ដែលពុំមែនជាម្ចាស់ដើមឡើយ ដូចនេះក្នុងចម្លើយពុំមានសិទ្ធិលើដីទំនាស់នេះទេ តាមការកំណត់នៃមាត្រា១៨០ នៃច្បាប់ភូមិបាលឆ្នាំ១៩៩២ ។

- យល់ឃើញថា ការដែលលោកហវចាកចេញពីដីទំនាស់ពីឆ្នាំ១៩៨៩ ដោយសារសង្គ្រាមនោះ គឺជាករណីប្រធានស័ក្ក ពុំអាចចាត់ទុកថាលោកបោះបង់ដីនេះចោល ដោយឆន្ទៈផ្ទាល់ឡើយ ។

- យល់ឃើញថា ការដែលអ្នកស្រីហធត ចុងចម្លើយ លើកឡើងនាសវនាការនេះថា អ្នកស្រីបានទិញដីនេះ ហើយបានកាប់ឆ្ការ និងដាំដំណាំរហូតបានទទួលផលនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា ពុំមានភស្តុតាងណាបញ្ជាក់ថា ឈ្មោះសោម សុខុម ដែលជាអ្នកលក់ដីឱ្យខ្លួន ជាម្ចាស់ដីនោះឡើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩២(ក)ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

ហេតុដូចនេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខគូក្ដី

១-ទទួលបណ្ដឹងសាទុក្ខលេខ៧៧ចុះថ្ងៃទី១៥-០៣-២០០១ របស់ឈ្មោះធហ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៩២(ក) ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីដែលភាគីលោកហវបានបង់នៅតុលាការកំពូលចំនួន១៩០០០៛គឺ៖

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡបញ្ជីកាន់ហិបប្រាក់ ។

ចំណាយក្នុងកិច្ចការប្រគល់ដីកាកោះចំនួន១៥០០០៛ សរុប១៩០០០៛ ។

បង្គាប់ឱ្យភាគីលោកធហ សងប្រាក់ចំនួន១៩.០០០៛ នេះទៅឈ្មោះហវវិញ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ ។